# ព្រះរាជក្រម

នស/រកម/១២០៥/០៤០

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

.....................................................................................................

.....................................................................................................

.....................................................................................................



៥

# ជំពូកទី ២

## ការកំណត់រយៈពេលអាទិភាពសម្រាប់លើកលែងពន្ធលើប្រាក់ចំណេញ ដល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

**មាត្រា ៧.-**

ដោយអនុលោមតាមមាត្រា ១៤ ថ្មី កថាខណ្ឌ ១៤.១ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៣ បានអនុញ្ញាតឱ្យគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មានសិទ្ធិទទួលបាននូវរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញដែលមានកំណត់ក្នុងច្បាប់ស្តីពីសារពើពន្ធ ។ រយៈពេលលើកលែងពន្ធនេះរួមមាន : រយៈពេលគន្លឹះ បូករយៈពេល៣(បី)ឆ្នាំ បូក រយៈពេលអាទិភាព ។ ចំនួនឆ្នាំនៃរយៈពេលអាទិភាពសម្រាប់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានកំណត់ដូចខាងក្រោម :

-គម្រោងវិនិយោគដែលមានលក្ខណៈជាឧស្សាហកម្មធុនស្រាល រយៈពេលអាទិភាពត្រូវបានកំណត់ដូចតទៅ :

• ទុនវិនិយោគក្រោម ៥.០០០.០០០(ប្រាំលាន)ដុល្លារអាមេរិក រយៈពេលអាទិភាពកំណត់ស្មើនឹង ០(សូន្យ) ឆ្នាំ ។

• ទុនវិនិយោគពី ៥.០០០.០០០(ប្រាំលាន) ដុល្លារអាមេរិក ដល់២០.០០០.០០០(ម្ភៃលាន) ដុល្លារអាមេរិក រយៈពេលអាទិភាពកំណត់ស្មើនឹង ១(មួយ) ឆ្នាំ ។

• ទុនវិនិយោគពី ២០.០០០.០០០(ម្ភៃលាន) ដុល្លារអាមេរិក ឡើងទៅ រយៈពេលអាទិភាពកំណត់ស្មើនឹង ២(ពីរ) ឆ្នាំ ។

-គម្រោងវិនិយោគដែលមានលក្ខណៈជាឧស្សាហកម្មធុនធ្ងន់ រយៈពេលអាទិភាពត្រូវបានកំណត់ដូចតទៅ :

• ទុនវិនិយោគក្រោម ៥០.០០០.០០០(ហាសិបលាន) ដុល្លាអាមេរិក រយៈពេលអាទិភាពកំណត់ស្មើនឹង ២(ពីរ) ឆ្នាំ ។

• ទុនវិនិយោគពី ៥០.០០០.០០០(ហាសិបលាន) ដុល្លាអាមេរិក ឡើងទៅរយៈពេលអាទិភាពកំណត់ស្មើនឹង ៣(បី) ឆ្នាំ ។

- គម្រោងវិនិយោគដែលមានលក្ខណៈជាទេសចរណ៍ រយៈពេលអាទិភាពត្រូវបានកំណត់ដូចតទៅ :

• ទុនវិនិយោគក្រោម ១០.០០០.០០០(ដប់លាន) ដុល្លាអាមេរិក រយៈពេលអាទិ-ភាពកំណត់ស្មើនឹង ០(សូន្យ) ឆ្នាំ ។

• ទុនវិនិយោគពី ១០.០០០.០០០(ដប់លាន) ដុល្លាអាមេរិក ឡើងទៅ រយៈពេលអាទិភាពកំណត់ស្មើនឹង ១(មួយ) ឆ្នាំ ។

- គម្រោងវិនិយោគក្នុងវិស័យកសិកម្មដែលមានលក្ខណៈជាដំណាំកសិកម្ម និងកសិ-ឧស្សាហកម្ម រយៈពេលអាទិភាពត្រូវបានកំណត់ដូចតទៅ :

• ដំណាំកសិកម្មរយៈពេលខ្លី រយៈពេលអាទិភាពកំណត់ស្មើនឹង ១(មួយ) ឆ្នាំ ។

• ដំណាំកសិកម្មរយៈពេលវែង និងកសិឧស្សាហកម្ម រយៈពេលអាទិភាពកំណត់ស្មើនឹង ២(ពីរ) ឆ្នាំ ។

-គម្រោងវិនិយោគដែលមានលក្ខណៈជាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រយៈពេលអាទិភាពត្រូវបានកំណត់ដូចតទៅ :

• ទុនវិនិយោគក្រោម ១០.០០០.០០០(ដប់លាន) ដុល្លាអាមេរិក រយៈពេលអាទិ-ភាព កំណត់ស្មើនឹង ១(មួយ) ឆ្នាំ ។

• ទុនវិនិយោគពី ១០.០០០.០០០(ដប់លាន) ដុល្លាអាមេរិក ដល់ ៣០.០០០.០០០ (សាមសិបលាន) ដុល្លាអាមេរិក រយៈពេលអាទិភាពកំណត់ស្មើនឹង ២(ពីរ) ឆ្នាំ ។

• ទុនវិនិយោគពី ៣០.០០០.០០០(សាមសិបលាន) ដុល្លាអាមេរិក ឡើងទៅ រយៈពេលអាទិភាព កំណត់ស្មើនឹង ៣(បី) ឆ្នាំ ។

## ជំពូកទី ៣

## ការខ្ចី និង ការធានារបស់រដ្ឋ

**មាត្រា ៨.–**

------------------------------------------------------------

------------------------------------------------------------

------------------------------------------------------------

-------------------------------------------------------------------

-------------------------------------------------------------------

-------------------------------------------------------------------

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១២.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣.–**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៣០ ខែ ៥ ឆ្នាំ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពាល-០៥១២.៥៧៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**គាត ឈន់**

លេខ:៤៩៨ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី៣១ ខែ ៥ ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**